c

# សេចក្តីថ្លែងការណ៍រួមរបស់សហគមន៍ជនជាតិដើមភាគតិចនៃព្រះរាជាណាចក្រកម្ពុជា
# ស្តីពី
# លទ្ធផលប្រមូលធាតុចូលក្នុងសេចក្តីព្រាងវិសោធនកម្មច្បាប់
# ស្តីពីតំបន់ការពារធម្មជាតិ និងច្បាប់ស្តីពីព្រៃឈើ
# នៅសណ្ឋាគារសោមាទេវីអង្គរ រីសត ក្រុងសៀមរាប
# ថ្ងៃទី ១៥-១៦ ខែសីហា ឆ្នាំ ២០២២

នៅថ្ងៃទី ១៥-១៦ ខែសីហា ឆ្នាំ ២០២២ ជនជាតិដើមភាគតិចបានធ្វើសិក្ខាសាលាពិគ្រោះយោបល់ ប្រមូលធាតុចូលដាក់ក្នុងសេចក្តីព្រាងវិសោធនកម្មច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ និងច្បាប់ស្តីពីព្រៃឈើ នៅ សណ្ឋាគារសោមាទេវីអង្គរ រីសត ក្រុង និងខេត្តសៀមរាប។

កិច្ចពិគ្រោះយោបល់នេះមានសមាសភាពចូលរួម **សរុបទាំងអស់ចំនួន ១៨១ នាក់** ក្នុងនោះមានតំណាងសហគមន៍ជនជាតិដើមភាគតិចចំនួន ១៥១ នាក់ ដែលមានស្ត្រី ៤៦ នាក់ តំណាងអង្គការ និងសមាគមជនជាតិដើមភាគតិចចំនួន ២៤ នាក់ ទីប្រឹក្សាជាជនជាតិដើមភាគតិចចំនួន ២នាក់ ទីប្រឹក្សាមិនមែនជាជន ជាតិដើម ភាគតិចចំនួន ១នាក់ មេធាវីជាជនជាតិដើមភាគតិចចំនួន ៥នាក់ និងតំណាងសហគមន៍ជាជនជាតិដើមភាគតិច ចូលរួមតាមរយៈ Zoom Online ចំនួន ១២ នាក់ សមាគមស្ត្រីជនជាតិដើមភាគតិចចំនួន ៣នាក់ និងមានការចូលរួមពី **ឯកឧត្តម យិន គឹមស៊ាន** អ្នកតំណាងរាស្ត្រមណ្ឌលសៀមរាប រួមទាំងក្រសួងមហាផ្ទៃ ក្រសួងអភិវឌ្ឍជនបទ អង្គការមិនមែនរដ្ឋាភិបាលជាតិ អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍចំនួន ២៤ នាក់ដែលបានចូលរួមដោយផ្ទាល់ និងតាមប្រព័ន្ធពីចម្ងាយ។ ក្នុងកិច្ចពិគ្រោយោបល់នេះ មានអំបូរជនជាតិដើមភាគតិចចំនួន ១៦ ជនជាតិរួមមាន ជនជាតិដើមភាគតិច ព្នង កួយ ស្ទួយ គ្រឹង ទំពួន ចារាយ ថ្មូន ព័រ ស្មៀង កាចក់ ស្អូច ជង លុន ខោញ ព្រៅ កាវ៉ែត ដែលមកពីបណ្តាខេត្តចំនួន ១២ គឺ ខេត្តក្រចេះ រតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ព្រះវិហារ កំពង់ធំ កំពង់ស្ពឺ ពោធិ៍សាត់ កោះកុង បន្ទាយមានជ័យ ព្រះសីហនុ និងបាត់ដំបង។

## កិច្ចពិគ្រោះយោបល់នេះមានគោលបំណងដូចខាងក្រោម៖

១.ដើម្បីបង្ហាញពីគោលបំណង និងដំណើរការកែប្រែ/វិសោធនកម្មច្បាប់ស្តីពីតំបន់ការពារធម្មជាតិឆ្នាំ ២០០៨ និងច្បាប់ស្តីពីព្រៃឈើឆ្នាំ២០០២ ក្រោមការដឹកនាំរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ដល់តំណាងសហគមន៍ជនជាតិដើមភាគតិចផ្ទាល់។

២.ផ្តល់ឱកាសឱ្យជនជាតិដើមភាគតិចបានចូលរួមពិភាក្សាពេញលេញ ពាក់ព័ន្ធទៅនឹងស្ថានភាពអនុវត្តច្បាប់កន្លងមកលើសិទ្ធិកាន់កាប់ដីធ្លី និងធនធានធម្មជាតិស្របតាមប្រពៃណីជនជាតិដើមភាគតិច ដើម្បីផ្តល់ធាតុចូលប្រកបដោយប្រសិទ្ធភាព និងពេញលេញលើខ្លឹមសារនៃសេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងច្បាប់ស្តីពីព្រៃឈើ ស្របតាមការទទួលស្គាល់សិទ្ធិជនជាតិដើមភាគតិចលើដីធ្លី ព្រៃឈើ និងធនធានធម្មជាតិតាមប្រពៃណីទំនៀមទំលាប់របស់ជនជាតិដើមភាគតិច និងស្របតាមលិខិតុបករណ៍ជាតិ និងអន្តរជាតិ។

៣. ដើម្បីជានាថាច្បាប់ដែលនឹងធ្វើវិសោធនកម្ម បានផ្តល់ផលប្រយោជន៍សមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច ដោយមិនប៉ះពាល់ដល់សិទ្ធិប្រពៃណីក្នុងការប្រកបមុខរបរចិញ្ចឹមជីវិត ការពារ និងគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងការប្រតិបត្តិជំនឿប្រពៃណីជនជាតិដើមភាគតិច។

ដោយផ្អែកលើគោលបំណង លទ្ធផល និងស្មារតីឯកភាពជាសមូហភាពនៃកិច្ចពិគ្រោះយោបល់របស់ជនជាតិដើមភាគតិចផ្តល់ធាតុចូលក្នុងសេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ច្បាប់ស្តីពីព្រៃឈើ យើងខ្ញុំជាជនជាតិដើមភាគតិចសូមអះអាងថា៖

ជនជាតិដើមភាគតិចមានសិទ្ធិស្មើគ្នាដូចប្រជាពលរដ្ឋដទៃទៀត ខណៈមនុស្សទាំងអស់មានសិទ្ធិ មានភាពផ្សេងពីគ្នា ជនជាតិដើមភាគតិចចាត់ទុកខ្លួនឯងថាមានភាពផ្សេងពីគេ ហើយត្រូវតែគោរពដល់សិទ្ធិនៃភាពផ្សេងពីគ្នានេះ។ ជនជាតិដើមភាគតិច និងបុគ្គលជាជនជាតិដើមភាគតិចមានសិទ្ធិមិនស្ថិតក្នុងកម្មវត្ថុនៃការបង្ខំឱ្យចាត់បញ្ចូល ឬចាត់ទុកសហគមន៍ខ្លួនឱ្យដូចគ្នានឹងសហគមន៍ដែលមានភាពផ្សេងគ្នាពីសហគមន៍ខ្លួន ដែលនាំឱ្យប៉ះពាល់ដល់សេដ្ឋកិច្ច សង្គម វប្បធម៌ដែលជាអត្តសញ្ញាណ ប្រពៃណី និងជំនឿសាសនារបស់ខ្លួន។

ជនជាតិដើមភាគតិច មានសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌របស់ខ្លួនដោយមានការទទួលស្គាល់ ការការពារ និងមានអភិបាលកិច្ច ស្របតាមទំនៀមទម្លាប់ប្រពៃណីវប្បធម៌ តាមផ្លូវច្បាប់ និងការអនុវត្តច្បាប់ ដោយគ្មានការរើសអើងក្នុងវិស័យធនធានធម្មជាតិ និងដីធ្លីទោះជាក្នុងរូបភាពណាក៏ដោយ។

ដោយបារម្ភថា ជនជាតិដើមភាគតិច ទទួលរងនូវអំពើអយុត្តិធម៌ជាប្រវត្តិសាស្ត្រ ដែលបណ្តាលមកពីការរើសអើង ក្នុងការដកហូតសិទ្ធិជនជាតិដើមភាគតិចលើការគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ធនធានធម្មជាតិ ដូចមានចែងនៅក្នុងខ្លឹមសារនៃសេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

**ដោយបារម្ភផងដែរថា សេចក្តីព្រាងវិសោធនកម្មច្បាប់ទាំងពីរ** ជាពិសេសសិទ្ធិក្នុងការចូលរួមពិគ្រោះយោបល់ដោយសុចរិត សិទ្ធិទទួលបាននូវព័ត៌មានពេញលេញ សិទ្ធិក្នុងការសម្រេចចិត្តជាសមូហភាពដោយគ្មានការគំរាមកំហែង បង្ខិតបង្ខំ និងសិទ្ធិក្នុងការអភិវឌ្ឍតាមសេចក្តីត្រូវការ និងផលប្រយោជន៍សមូហភាពរបស់ខ្លួន ដើម្បីជានាដល់ភាពគង់វង្សនូវវប្បធម៌ប្រពៃណី ជំនឿសាសនារបស់ខ្លួន។

ដោយទទួលស្គាល់ថា សិទ្ធិជនជាតិដើមភាគតិចមានចែងក្នុងច្បាប់ភូមិបាលឆ្នាំ ២០០១ ច្បាប់ស្តីពីព្រៃឈើឆ្នាំ ២០០២ និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិឆ្នាំ ២០០៨ សេចក្តីប្រកាសអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិជនជាតិដើមភាគតិច ឆ្នាំ ២០០៧ អនុសញ្ញាលេខ ១១១ ស្តីពីសិទ្ធិការងារ និងមុខរបរ។

## សេចក្តីថ្លែងការណ៍អំពីបញ្ហា និងក្តីកង្វល់របស់សហគមន៍ជនជាតិដើមភាគតិច៖

១. ការកំណត់ពាក្យសហគមន៍មូលដ្ឋាននៅក្នុងសេចក្តីព្រាងវិសោធនកម្មច្បាប់ទាំងពីរ មិនអាចជំនួសឱ្យសហគមន៍ជនជាតិដើមភាគតិច ឬពលរដ្ឋជនជាតិដើមភាគតិចបានឡើយ ដោយសារសហគមន៍ជនជាតិដើមភាគតិចមានដើមកំណើត ជាតិពន្ធុ ភាសា សង្គមវប្បធម៌ ប្រពៃណីមានភាពផ្សេងពីគេ ជាពិសេសការប្រតិបត្តិ ក្នុងការប្រកបមុខរបរចិញ្ចឹមជីវិត ហើយមានទំនាក់ទំនងផ្ទាល់ជាមួយដីធ្លី និងធនធានធម្មជាតិខុសពីសហគមន៍មូលដ្ឋានផ្សេងៗដែលមិនមែនជាសហគមន៍ជនជាតិដើមភាគតិច។ សហគមន៍ជនជាតិដើមភាគតិចគឺ ជាក្រុមមនុស្សដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាតាំងពីកំណើតពូជពង្សដូនតារបស់ខ្លួនដែលសមាជិកទាំងអស់បង្ហាញនូវការឯកភាពនៃជាតិពន្ធុ សង្គម វប្បធម៌ សេដ្ឋកិច្ចប្រតិបត្តិ របៀប

រស់នៅតាមប្រពៃណី និងជាំផុះលើដីដែលខ្លួនកាន់កាប់តាមក្បួនខ្នាតទំនៀមទំលាប់នៃការប្រើប្រាស់ជាសមូហភាព។ ដូចនេះ **សហគមន៍មូលដ្ឋាន** និង **សហគមន៍ជនជាតិដើមភាគតិច** មិនដូចគ្នាទេ។

២. ច្បាប់ស្តីពីព្រៃឈើបានប្រកាសឱ្យប្រើដោយព្រះរាជក្រមអស់រយៈពេល ២០ ឆ្នាំ និងច្បាប់ស្តីពី តំបន់ការពារធម្មជាតិ១៤ ឆ្នាំ បានធ្វើឱ្យសមាជិកសហគមន៍ជនជាតិដើមភាគតិច(ជាបុគ្គល និងជាក្រុម)មួយចំនួនបាននឹងកំពុងប្រឈមបញ្ហាជាច្រើនក្នុងការអនុវត្តសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌របស់ខ្លួនរួមមាន៖

- បែបបទនីតិវីធី និងដំណើរការក្នុងការបង្កើតសហគមន៍មានលក្ខណៈស្មុគស្មាញ ចំណាយពេលយូរ និងប្រើប្រាស់ធនធានច្រើន។
- ការកំណត់ទីតាំងតំបន់ស្នូល តំបន់អភិរក្ស តំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍ ដោយគ្មានការដឹងឮ ចូលរួម និងឯកភាពពីសមូហភាពជនជាតិដើមភាគតិចក្នុងទីតាំងដែលជនជាតិដើមភាគតិចបាន និងកំពុងរស់នៅ ទោះបីជាមានការដោះដូរសំណងពីរដ្ឋក៏ដោយ ប៉ុន្តែវាបានប្រាសចាកពីលក្ខខណ្ឌប្រពៃណីវប្បធម៌ សាសនា អត្តសញ្ញាណដើមរបស់ជនជាតិដើមភាគតិច ធ្វើឱ្យជនជាតិដើមភាគតិចមួយចំនួន ត្រូវបានឃាត់ខ្លួន បញ្ជូនទៅតុលាការ ដោយសារការប្រតិបត្តិកសិកម្មប្រពៃណី មានចម្ការវិលជុំ ឬចម្ការពនេចរ ដើម្បីចិញ្ចឹមជីវិត និងបានបាត់បង់ដីធ្លី ដីជំនឿសាសនា ដីលំនៅដ្ឋាន ដីកសិកម្ម ដីឬទីតាំងអាស្រ័យផល។ល។ បុគ្គល គ្រួសារ និងសហគមន៍ដែលមិនបានរៀបចំជាសហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើមិនទទួលបានផលប្រយោជន៍ និងសិទ្ធិការពារ អភិរក្ស ធនធានធម្មជាតិ។
- សហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើ មិនគ្របដណ្តប់ទៅលើទីកន្លែង ដីប្រើប្រាស់អាស្រ័យផលតាមប្រពៃណី និងព្រៃជំនឿសាសនាទាំងអស់ដែលជនជាតិដើមភាគតិចធ្លាប់មានជាក់ស្តែងពីមុនមក។
- ក្រៅពីឯកសារកិច្ចព្រមព្រៀងសហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិពុំដែលអាជ្ញាធរណាមួយចេញឯកសារ ឬលិខិតសំគាល់សិទ្ធិប្រើប្រាស់តាមប្រពៃណី សិទ្ធិជំនឿ លើទីតាំងនានាក្នុងតំបន់ព្រៃឈើ តំបន់ការពារ ឬតំបន់អភិរក្សធម្មជាតិជូនជនជាតិដើមភាគតិចឡើយ។ កាលបើសហគមន៍ ក្រុម ឬគ្រួសារ មិនមានឯកសារសំគាល់សិទ្ធិទាំងនេះ បានផ្តល់ផលវិបាកមួយចំនួនដូចជា ពុំមានភស្តុតាងសំអាងផ្លូវច្បាប់ចំពោះមុខតុលាការ ចំពោះភាគីវិវាទ និងត្រូវបានរដ្ឋបាលព្រៃឈើ ឬរដ្ឋបាលការពារ និងអភិរក្សធម្មជាតិចាត់ទុកថា ជាសកម្មភាពពុំស្របច្បាប់ ចាប់ផាកពិន័យតាមអំពើចិត្តយ៉ាងធ្ងន់ធ្ងរ ហើយករណីមួយចំនួនបានប្តឹងចោទប្រកាន់តាមផ្លូវតុលាការ។
- បុគ្គលជនជាតិដើមភាគតិចភាគច្រើនមានការភាន់ច្រឡំ មិនច្បាស់លាស់អំពីគោលបំណងផែនការយុទ្ធសាស្ត្រគ្រប់គ្រង អភិរក្ស និងប្រើប្រាស់ធនធានធម្មជាតិនៃសហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិដែលត្រូវបានបង្កើតឡើងក្នុងភូមិ ឬសហគមន៍របស់ខ្លួន។
- ជនជាតិដើមភាគតិចរងផលប៉ះពាល់ផ្ទាល់យ៉ាងធ្ងន់ធ្ងរដោយសារគម្រោងអភិវឌ្ឍន៍លើដីព្រៃដែលធ្លាប់ប្រើប្រាស់ និងគោរពប្រតិបត្តិតាមប្រពៃណី។ ច្បាប់បានកំណត់ដីព្រៃទាំងនេះជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ហើយត្រូវបានធ្វើអនុប្រយោគទៅជាដីឯកជនរបស់រដ្ឋដើម្បីអាចចាត់ចែងជួល ឬសម្បទានឱ្យក្រុមហ៊ុនឯកជនអភិវឌ្ឍន៍ ដោយគ្មានការពិគ្រោះយោបល់ដោយសុចរិត ពុំមាន

ពេលវេលាគ្រប់គ្រាន់ មិនទទួលបានព័ត៌មានគ្រប់គ្រាន់ និងមិនមានការឯកភាពពីសមូហភាពជនជាតិដើមភាគតិចជាមុន។

- មន្ត្រីអនុវត្តច្បាប់ថ្នាក់ក្រោមជាតិ បកស្រាយ និងអនុវត្តច្បាប់មិនច្បាស់លាស់ ហើយជាទូទៅ ចោទប្រកាន់ថា សហគមន៍ជនជាតិដើមភាគតិចដែលមានស្រាប់ មិនមែនជាសហគមន៍ស្របច្បាប់ ហើយសួររកលិខិតបញ្ជាក់អំពីសហគមន៍ដែលទទួលស្គាល់ដោយអាជ្ញាធរវដ្ឋបាល ក្នុងខណៈពេលដែលមិនមានអាជ្ញាធរណាមួយទទួលខុសត្រូវក្នុងការរៀបចំ និងចេញលិខិតទទួលស្គាល់ឱ្យសហគមន៍ជនជាតិដើមភាគតិចនៅឡើយ។
- ជនជាតិដើមភាគតិច ពុំដឹងថាតំបន់ណាដែលជាតំបន់ស្នូល ឬតំបន់អភិរក្ស ដោយសារពុំទាន់មានការកំណត់តំបន់ទាំងបួន និងបោះបង្គោលព្រំតាមតំបន់នីមួយៗ ក្នុងតំបន់ការពារភាគច្រើន ដែលធ្វើឱ្យសមាជិកសហគមន៍ជនជាតិដើមភាគតិចវងេ្រគាះ និងងាយធ្លាក់ក្នុងការចោទប្រកាន់នៅពេលប្រើប្រាស់ដីទៅតាមសិទ្ធិរស់នៅរបស់ខ្លួន។

ដើម្បីឆ្លើយតប ឬដោះស្រាយបញ្ហា និងការប្រឈមរួមដែលកើតចេញពីភាពខ្វះខាតនូវខ្លឹមសារ និងអភិបាលកិច្ចសិទ្ធិ ព្រមទាំងបញ្ហាអនុវត្តច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងច្បាប់ស្តីពីព្រៃឈើជនជាតិដើមភាគតិចបានឯកភាពគ្នារៀបចំពិគ្រោះយោបល់ចំនួន ៤លើក រួមទាំងកិច្ចពិគ្រោះយោបល់នេះដើម្បីប្រមូល និងដាក់ធាតុចូលក្នុងសេចក្តីព្រាងវិសោធនកម្មច្បាប់ទាំងពីរនេះឱ្យមានអភិបាលកិច្ចសិទ្ធិគ្រប់គ្រាន់ចំពោះជនជាតិ ដើមភាគតិចដោយដាក់បញ្ចូលសិទ្ធិបុគ្គល និងសមូហភាពជនជាតិដើមភាគតិច ក្នុងការទទួលបានព័ត៌មាន មានពេលវេលាគ្រប់គ្រាន់ជាមុន មានការពិគ្រោះយោបល់ដោយសុចរិត និងឯកភាពជាសមូហភាព ដោយគ្មានការបំភិតបំភ័យ គំរាមកំហែង ឬរឹតត្បិតសិទ្ធិសេរីភាពក្នុងការប្រកបមុខរបរធ្វើចម្ការពនេចរ ឬចំការវិលជុំ។ ធាតុចូលទាំងនេះផ្អែកទៅលើទំនៀមទំលាប់ប្រពៃណីរបស់ជនជាតិដើមភាគតិច និងបទដ្ឋានគតិយុត្តិអន្តរជាតិ រួមមានគោលការណ៍ណែនាំដោយស្ម័គ្រចិត្តស្តីពីអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវ លើការកាន់កាប់ដី ជលផល និងព្រៃឈើក្នុងបរិបទសន្តិសុខស្បៀង (VGGT) សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស សេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច អនុសញ្ញាអង្គការអន្តរជាតិខាងការងារលេខ១១១ ស្តីពីការរើសអើងការងារ និងមុខរបរ និងគតិយុត្តិជាតិ រួមមានច្បាប់ភូមិបាលឆ្នាំ២០០១ គោលនយោបាយ អភិវឌ្ឍជនជាតិដើមភាគតិច អនុក្រឹត្យលេខ ៨៣ ស្តីពីនីតិវិធី និងដំណើរការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច គោលនយោបាយជាតិ ព្រមទាំងលទ្ធផលនៃការពិគ្រោះយោបល់នៅខេត្តរតនគិរី និងខេត្តមណ្ឌលគិរីរបស់ ក្រុមអង្គការ សមាគម ក្រុមមេធាវីជនជាតិដើមភាគតិច បានសម្រេចផ្តល់នូវធាតុចូល និងធ្វើសេចក្តីថ្លែងការណ៍រួម អំពីធាតុចូលចំនួន ៨ដូចខាងក្រោម៖

**ធាតុចូលទី១៖** ស្នើ ឱ្យបញ្ញតិ " **បុគ្គលជនជាតិដើមភាគតិច និងសហគមន៍ជនជាតិដើមភាគតិច** " នៅក្នុងបទប្បញ្ញត្តិវិសោធនកម្មច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងច្បាប់ស្តីពីព្រៃឈើ។ បទប្បញ្ញត្តិនៅក្នុងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងច្បាប់ស្តីពីព្រៃឈើ ពុំអាចបញ្ញតិ "សហគមន៍មូលដ្ឋាន" ជំនួសឱ្យ ឬសមាហរណកម្មជាមួយ "សហគមន៍ជនជាតិដើមភាគតិច" បានឡើយ ពីព្រោះសហគមន៍ជនជាតិដើមភាគតិចមានភាពផ្សេងគ្នាពីសហគមន៍មូលដ្ឋានដាច់ស្រឡះ។ ភាពផ្សេងគ្នាមានជាអាទិ៍ ដើមកំណើត ពូជពង្សដូនតា ទំនៀមទំលាប់ប្រពៃណី វប្បធម៌ ប្រព័ន្ធ និងរចនាសម្ព័ន្ធសង្គម។ សមាជិកទាំងអស់បង្ហាញនូវការឯកភាពនៃជាតិពន្ធុ វិជាន

ប្រពៃណី ភាសា ចំណេះដឹង ជំនឿ ប្រតិបត្តិសាសនា ពហុសាសនាផ្សារភ្ជាប់យ៉ាងជិតស្និទជាមួយ ព្រៃឈើ ដីធ្លី ធនធានធម្មជាតិ និងភាពអចិន្ត្រៃយ៍។

អំពីនិយមន័យ ឬការកំណត់អំពីជនជាតិដើមភាគតិច និងសហគមន៍ជនជាតិដើមភាគតិច ត្រូវតែចែងដាច់ដោយឡែកពីសហគមន៍មូលដ្ឋាន ក្នុងបទប្បញ្ញត្តិច្បាប់វិសោធនកម្មទាំងពីរនេះ ។ ការស្នើនូវតម្រូវការនេះដោយមូលហេតុ ៖

- សហគមន៍ជនជាតិដើមភាគតិច ខុសគ្នាពីសហគមន៍មូលដ្ឋាន ។ សហគមន៍ ឬក្រុមជនជាតិដើមភាគតិច មានលក្ខណៈដោយឡែកផ្នែកសង្គម និងវប្បធម៌ ដែលនាំឲ្យសង្គមជនជាតិដើមភាគតិច មិនដូចគ្នានឹងសហគមន៍មូលដ្ឋាន ឬសហគមន៍ផ្សេងៗទេ។
- ការកំណត់និយមន័យសហគមន៍មូលដ្ឋាន សំដៅដល់ជនជាតិដើមភាគតិច ឬសហគមន៍ជនជាតិដើមភាគតិច អាចនាំឲ្យប៉ះពាល់អត្តសញ្ញាណ និងលក្ខណៈដោយឡែកផ្នែកវប្បធម៌ និងសង្គម និងអាចនាំឲ្យមានការបកស្រាយខុសៗគ្នា នៅពេលសិទ្ធិជនជាតិដើមភាគតិចត្រូវបានប៉ះពាល់ឬបំពាន ជាពិសេសពេលដែលរឿងចូលដល់នីតិវិធីតុលាការ ឬរដ្ឋបាល។
- ច្បាប់ភូមិបាល បានផ្តល់និយមន័យច្បាស់លាស់រួចហើយ។
- សិទ្ធិជំនឿ ប្រពៃណី វប្បធម៌ និងសង្គមរបស់ជនជាតិដើមភាគតិច មានលក្ខណៈអចិន្ត្រៃយ៍ ចំណែកសិទ្ធិកើតពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើ គឺជាសិទ្ធិកើតចេញពីកិច្ចព្រមព្រៀងរវាងរដ្ឋ និងសហគមន៍ ដែលមានរយៈពេលកំណត់។ លើសពីនេះជនជាតិដើមភាគតិចជាច្រើនមិនមានចំណេះដឹង មិនដឹងព័ត៌មាន មិនមានសមត្ថភាពបង្កើតសហគមន៍ តាមគោលបំណងច្បាប់ទាំងពីរនេះ ដោយខ្លួនឯងទេ។
- ការចែងដាក់លាក់ដោយឡែកអំពីជនជាតិដើមភាគតិចក្នុងសេចក្តីព្រាងវិសោធនកម្មច្បាប់ទាំងពីរ មានសង្គតិភាពជាមួយច្បាប់ផ្សេងៗទៀតជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា ដូចជា ក្រមរដ្ឋប្បវេណី និងច្បាប់ភូមិបាល។

**ធាតុចូលទី ២៖** ស្នើឱ្យមានបទប្បញ្ញត្តិនៅក្នុងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងច្បាប់ស្តីពីព្រៃឈើត្រូវតែបញ្ញតិ ទទួលស្គាល់សិទ្ធិ និងបញ្ញតិអភិបាលកិច្ចធានាសិទ្ធិលើមុខរបរប្រពៃណីនៃ " **ចម្ការពនេរចរ ឬ ចម្ការវិលជុំ** " ។

និយមន័យ ឬរបៀបនៃការប្រតិបត្តិកសិកម្មប្រពៃណីក្នុងការធ្វើចម្ការពនេរចរ ឬចម្ការវិលជុំ គឺជារបៀបប្រើប្រាស់ដីតាមទំនៀមទម្លាប់នៃការដាំដុះដំណាំចម្រុះច្រើនមុខដូចជាស្រូវបូត បន្លែ ពោត ល្ង ម្ទេស ត្រប់ ននោង ល្ពៅ ត្រសក់ ត្រឡាច ដំឡូងច្រើនប្រភេទ សណ្តែក ត្រាវ ។ល។ ទីតាំងដីមានច្រើនកន្លែង ឆ្នាំនេះធ្វើកន្លែងមួយបានរយៈពេលមួយទៅពីរឆ្នាំ ប្តូរទៅធ្វើកន្លែងមួយទៀត រហូតដល់ប្រាំបីទៅដប់ឆ្នាំក្រោយទើបដល់វេនវិលទៅធ្វើនៅទីតាំងដំបូងវិញ គឺប្រតិបត្តិវិលចុះវិលឡើងក្នុងដីដែលធ្លាប់កាន់កាប់ និងប្រើប្រាស់កន្លងមក ដែលក្នុងនោះរួមមានការកាប់ព្រៃចម្ការចាស់ ឬក្បាលដីដែលមានដុះដើមឈើឡើងវិញនាំឱ្យដីមានជីជាតិតាមធម្មជាតិ។

ចម្ការពនេចរ ឬចម្ការវិលជុំមួយកន្លែងបន្ទាប់ពីបោះបង់ទុករយៈពេលច្រើនឆ្នាំ បានប្តូរទៅទីតាំងផ្សេងៗ បានបន្សល់ទុកនូវប្រភេទពូជដំណាំបុរាណចម្រុះមួយចំនួនអាចដុះសល់ចម្រុះជាមួយព្រៃ ឬរុក្ខជាតិផ្សេងៗដែលដុះឡើងវិញបាន ហើយអាចផ្តល់ជាចំណី និងជម្រកដល់សត្វព្រៃជាច្រើនប្រភេទផងដែរ។

ការប្រតិបត្តិកសិកម្មប្រពៃណីនេះ មានតម្លៃមិនអាចកាត់ថ្លៃជាប្រាក់បាន នូវទំនាក់ទំនងគ្នាចំពោះសេដ្ឋកិច្ចប្រពៃណីវប្បធម៌ និងសង្គម របស់ជនជាតិដើមភាគតិច។ ទំនាក់ទំនងផ្នែកសេដ្ឋកិច្ចពួកយើងអាចផ្គត់ផ្គង់ចំណី

អាហារធម្មជាតិសម្រាប់សុខភាព និងជីវភាពរស់នៅ ការដោះដូរផលនិងពូជដំណាំគ្នាទៅវិញទៅមក មានការផ្សារភ្ជាប់ជាមួយប្រពៃណីវប្បធម៌ ដូចជា ចំណេះដឹងអំពីរបៀបប្រតិបត្តិអារក្សមុនពេលកាប់ឆ្ការ មុនពេលដាំដំណាំ ក្រោយពេលដាំដំណាំ ចំណេះដឹងពីរបៀបរក្សាគ្រាប់ពូជ របៀបដាំ របៀបប្រមូលផលដំណាំចម្រុះឱ្យស្របតាមរដូវអាកាសធាតុ ស្ថានភាពដីប្រើប្រាស់ ចំណេះដឹងរបៀបថែរក្សាផលដំណាំក្នុងចំការ និងផ្សារភ្ជាប់ជាមួយទំនាក់ទំនងសង្គមដែលនាំឱ្យមានសាមគ្គីភាពល្អរបស់សមាជិកសហគមន៍ជនជាតិដើមភាគតិចដូចជាសកម្មភាពជួយគ្នា ប្រវាស់ដៃគ្នាពេលធ្វើចម្ការ ពេលដាំ មើលថែចំការឱ្យគ្នាទៅវិញទៅមកជាមួយអ្នកចម្ការជិតខាង។ល។

តម្លៃជាងនេះទៅទៀត ចំការវិលជុំ ឬចម្ការពនេចរ មានតម្លៃក្នុងដំណើរ សង្វាក់និរន្តរភាពបរិស្ថានធម្មជាតិដែលជាប្រយោជន៍សាធារណៈ ប្រយោជន៍មនុស្ស សត្វ ទឹក ដី ខ្យល់ ពិភពលោក និងភពផែនដីទាំងមូល។ ដំណើរជានិរន្តរភាពក្នុងន័យនេះ គឺអនុញ្ញាតឱ្យដើមឈើ រុក្ខជាតិ ព្រៃដុះឡើងវិញកុំឱ្យទឹកហូរច្រោះដីនាំទៅលុបខ្សែទឹកហូរដូចជាប្រឡាយ អូរ ស្ទឹង បណ្ដាលឱ្យធ្លាប់រាក់បាត់បង់ទីជម្រកត្រី បង្កើតគុណភាពដីឡើងវិញធ្វើឱ្យដីមានជីវជាតិល្អ។ បើតាមអ្នកវិទ្យាសាស្ត្រផ្នែកអាកាសធាតុ បានសិក្សាឃើញថាកូនឈើ និងដើមឈើតូចៗមានសមត្ថភាព ឬលទ្ធភាពស្រូប និងផ្ទុកកាបូនបានច្រើន រីឯដើមឈើមានអាយុកាលចាស់ៗមានសមត្ថភាពផ្ទុកកាបូនបានតិចតួច ឬហៅថាឆ្អែតកាបូន។ ត្រង់ចំណុចនេះ របៀប ឬចំណេះដឹងរបស់ជនជាតិដើមភាគតិចប្រតិបត្តិ ចំការវិលជុំ ឬចំការពនេចរដែលផ្ដល់ឱកាសឱ្យព្រៃ និងដើមឈើតូចៗដុះឡើងវិញមានសមត្ថភាព និងលទ្ធភាពស្រូប និងផ្ទុកកាបូនបានច្រើនចូលរួមសម្រាលដល់កំហូចបរិស្ថាន និងភពផែនដីទាំងមូល។

នេះជាគុណតម្លៃនៃរបៀប និងចំណេះដឹងក្នុងការប្រតិបត្តិចម្ការវិលជុំ ឬចម្ការពនេចររបស់ជនជាតិដើមភាគតិច ដែលមិនមែនជាការកាប់រានដីព្រៃ ឬដីថ្មីដើម្បីបំផ្លិចបំផ្លាញ និងធ្វើជាកម្មសិទ្ធិឡើយ ក៏ប៉ុន្តែជាការប្រតិបត្តិប្រើប្រាស់សម្រាប់ដាំដំណាំចាំបាច់សម្រាប់គ្រួសារ ប្រពៃណីវប្បធម៌ សង្គម និងបរិស្ថាន។

ការបដិសេធ ឬការដាក់បញ្ញត្តិហាមការប្រកបមុខរបរចម្ការវិលជុំ ឬចម្ការពនេចរនេះជាការប៉ះពាល់ធ្ងន់ធ្ងរដល់សិទ្ធិប្រពៃណី និងសេដ្ឋកិច្ចរបស់ជនជាតិដើមភាគតិចជាក់ស្ដែង ព្រមទាំងបង្ហាញពីការរើសអើងក្នុងមុខរបរប្រពៃណីរាប់រយពាន់ឆ្នាំមកហើយ។ ឧទាហរណ៍៖ នៅខេត្តព្រះវិហារ តំបន់អភិរក្សសត្វត្មាត មានការប្រកបមុខរបរចម្ការពនេរចរ ឬវិលជុំនៅទីនោះតាំងពីមុនច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ ច្បាប់ស្ដីពីព្រៃឈើ ច្បាប់ភូមិបាល និងមុនក្រុមអភិរក្សកំណត់តំបន់នោះជាតំបន់ការពារធម្មជាតិមកម្លេះ ហើយមកដល់បច្ចុប្បន្ន តំបន់នោះ សត្វត្មាតក៏មានច្រើន សត្វផ្សេងទៀតក៏មានច្រើន ផ្ទុយពីតំបន់ដែលមានចម្ការមិនមែនពនេចរឆ្ងាយណាស់។ ហេតុដូច្នេះសកម្មភាពចម្ការពនេចរ ឬចម្ការវិលជុំពុំប៉ះពាល់បរិស្ថាន និងធនធានធម្មជាតិឡើយ ផ្ទុយមកវិញ ការយល់ថា ជនជាតិដើមភាគតិចធ្វើចម្ការវិលជុំ ឬពនេរចរជាសកម្មភាពបំផ្លិចបំផ្លាញ និងប៉ះពាល់ធនធានព្រៃឈើ ឬធនធានធម្មជាតិ គឺជាការខ្វះការសិក្សាស្វែងយល់អំពីការប្រតិបត្តិជាក់ស្ដែង ឬជាផ្នត់គំនិតរើសអើងលើមុខរបរប្រពៃណីរបស់ជនជាតិដើមភាគតិចជាទូទៅ។

**ធាតុចូលទី ៣៖** ស្នើច្បាប់វិសោធនកម្មនៃច្បាប់ទាំងពីរនេះ ត្រូវតែមានមាត្រាជាក់លាក់បញ្ញតិអំពី **"អភិបាលកិច្ចសិទ្ធិធម្មានុរូប"** ដូចជាសិទ្ធិលើតំបន់ និងទីតាំងប្រើប្រាស់ អាស្រ័យផលតាមប្រពៃណី សិទ្ធិសាសនា សិទ្ធិជំនឿសក្ការៈបូជារបស់ជនជាតិដើមភាគតិច៖

៣.១. ច្បាប់ត្រូវបញ្ញត្តិ " **វិមជ្ឈការឱ្យរដ្ឋបាលមូលដ្ឋានឃុំ សង្កាត់មានសិទ្ធិ និងតម្លៃគតិយុត្តិ ចេញឯកសារសំគាល់** " សិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យផល សិទ្ធិជំនឿ សាសនា ជាលក្ខណៈរូបវន្តបុគ្គលឬនីតិបុគ្គលរបស់ជនជាតិដើមភាគតិច តំបន់ និងទីតាំងដែលធ្លាប់មានជាក់ស្តែង។

បើផ្អែកលើការឆ្លុះបញ្ចាំងច្បាប់ទាំងពីរនេះ មិនទាន់មានបទបញ្ញត្តិណាមួយ តម្រូវឱ្យអាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិចេញ " **ឯកសារ ឬលិខិតសំគាល់សិទ្ធិ** " តំបន់ និងទីតាំងប្រើប្រាស់ អាស្រ័យផល ជំនឿ សាសនា ជាលក្ខណៈរូបវន្តបុគ្គល ឬនីតិបុគ្គល ជនជាតិដើមភាគតិចដែលធ្លាប់មានជាក់ស្តែងឡើយ ហើយពេលមានចំណាត់ការចំពោះមុខច្បាប់ ចំពោះមុខតុលាការ ឬអាជ្ញាធររដ្ឋ គឺចៅក្រម ឬមន្ត្រីរដ្ឋ តែងតែសួររក និងទាមទាររកលិខិត ឬឯកសារសំគាល់សិទ្ធិជាប្រពៃណីលើតំបន់ពាក់ព័ន្ធទាំងនោះ ដែលចេញដោយអាជ្ញាធររដ្ឋ ជាហេតុនាំឱ្យជនជាតិដើមភាគតិចរងគ្រោះដោយអយុត្តិធម៌ ដោយសារតែគ្មានឯកសារភស្តុតាងសំអាងចំពោះមុខតុលាការ និងអាជ្ញាធររដ្ឋ។

៣.២. ត្រូវមានមាត្រាជាក់លាក់បញ្ញត្តិ " **យន្តការឯកភាពជាសមូហភាព ពិគ្រោះយោបល់ពេញលេញដោយសុចរិត** " ក្នុងការចូលរួមកំណត់តំបន់ទីតាំង សិទ្ធិជាប្រពៃណីតាមស្ថានភាពជាក់ស្តែងរបស់ជនជាតិដើមភាគតិច។

៣.៣. សេចក្តីព្រាងវិសោធនកម្មច្បាប់ទាំងពីរនេះត្រូវតែមានមាត្រាជាក់លាក់ " **ទទួលស្គាល់នូវការអះអាងអំពីទីតាំង ទំហំ ប្រភេទប្រើប្រាស់ អាស្រ័យផល ជំនឿសាសនា សក្ការៈបូជាជាក់ស្តែងសម្រាប់ចុះបញ្ជីកម្មសិទ្ធិដីជាសមូហភាព និងសម្រាប់ចុះបញ្ជីផ្សេងៗទៀតដែលមិនមែនជាកម្មសិទ្ធិលើអចលនវត្ថុ** " ជាជាងបដិសេធ ឬហាមឃាត់សិទ្ធិទាំងនេះដោយស្ថាប័នរដ្ឋ។

៣.៤. នៅក្នុងសេចក្តីព្រាងវិសោធនកម្មច្បាប់ទាំងពីរត្រូវមានមាត្រាជាក់លាក់បញ្ញត្តិពី " **យន្តការ និងវិធានការដោះស្រាយ តាមគោលការណ៍គណនេយ្យភាពក្នុងអភិបាលកិច្ចល្អ** " នៅពេលមានការដកហូត និងប៉ះពាល់សិទ្ធិប្រើប្រាស់ អាស្រ័យផល សិទ្ធិជំនឿ និងសាសនាណាមួយរបស់ជនជាតិដើមភាគតិច។ ឧទាហរណ៍៖ មាត្រា ២២ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិដែលនៅជាធរមានចែងថា " **រដ្ឋទទួលស្គាល់ និងធានាសិទ្ធិប្រើប្រាស់ជាលក្ខណៈប្រពៃណី ទំនៀមទម្លាប់ ជំនឿសាសនារបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចដែលរស់នៅក្នុងតំបន់ការពារធម្មជាតិ** " ក៏ប៉ុន្តែច្បាប់នេះមិនបានចែង ផ្តល់អាណត្តិ តួនាទីដល់អង្គការរដ្ឋថ្នាក់ណាមួយឱ្យធ្វើអភិបាលកិច្ចសិទ្ធិ (មិនមែនកម្មសិទ្ធិ)ទាំងនោះ ក្នុងប្រព័ន្ធរដ្ឋបាល កំរិតណាមួយជាពិសេសថ្នាក់ឃុំសង្កាត់ ឬស្រុកដែលនៅជិតប្រជាពលរដ្ឋ និងជនជាតិដើមភាគតិច។

**ធាតុចូលទី ៤៖** ស្នើសេចក្តីព្រាងវិសោធនកម្មច្បាប់ទាំងពីរនេះ គួរមាន " **ជំពូកមួយដោយឡែក** " (ដូចច្បាប់ភូមិបាល) ស្តីពីការកំណត់ ការទទួលស្គាល់ ការការពារសិទ្ធិ និងអភិបាលកិច្ចសិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យផល សិទ្ធិជំនឿ សាសនា វប្បធម៌ រួមទាំងអំពីរបៀបដោះស្រាយ ទំនាស់ ឬវិវាទនានាកាលណាមានហេតុការណ៍ប៉ះពាល់ ដោយពិចារណាអំពីវិធានប្រពៃណីរបស់ជនជាតិដើមភាគតិច មុននឹងឈានដល់ការដាក់ទោស ដាក់ពន្ធនាគារលើសមាជិកជាជនជាតិដើមភាគតិច។

**ធាតុចូលទី ៥ ៖** ស្នើរយៈពេលកិច្ចព្រមព្រៀងសហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិ គួរមានរយៈពេល " **ដូចកិច្ចសន្យាដីសម្បទានសេដ្ឋកិច្ចដែរ (៥០ ឬ៩៩ឆ្នាំ) ហើយមិនគួរផ្អាក ឬលុបកិច្ចព្រមព្រៀងសហគមន៍ឡើយ** " កាលបើសហគមន៍បានអនុវត្តត្រឹមត្រូវតាមកិច្ចព្រមព្រៀង។

**ធាតុចូលទី ៦ ៖** ស្នើសេចក្តីព្រាងវិសោធនកម្មច្បាប់ទាំងពីរនេះ គួរដាក់បញ្ញត្តិឱ្យរដ្ឋ " **ផ្តល់ធនធានថវិកាជាតិ** " ប្រចាំឆ្នាំ ដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍសហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិ ឱ្យកាន់តែមានប្រសិទ្ធភាព និងនិរន្តរភាព។

**ធាតុចូលទី ៧ ៖** ស្នើសេចក្តីព្រាងវិសោធនកម្មច្បាប់ទាំងពីរនេះ គួរដាក់បញ្ញត្តិកាតព្វកិច្ចឱ្យរដ្ឋ " **អនុវត្តគោលការណ៍ នៃការស្នើសុំការឯកភាពជាមុន ដោយសេរីបន្ទាប់ពីទទួលបានព័ត៌មានត្រឹមត្រូវ និងពេលវេលាគ្រប់គ្រាន់ជាមុន** " ពីសមូហភាពសហគមន៍ជនជាតិដើមភាគតិច មុននឹងសម្រេចលុបកិច្ចព្រមព្រៀង ឬដកហូតដីព្រៃសហគមន៍ ឬតំបន់ការពារធនធានធម្មជាតិពីសហគមន៍ជនជាតិដើមភាគតិច។

**ធាតុចូលទី ៨ ៖** ស្នើសេចក្តីព្រាងវិសោធនកម្មច្បាប់ទាំងពីរនេះ គួរមានមាត្រាដាក់លាក់បញ្ញត្តិអំពី " **ការកំណត់ទំហំ ទីតាំង ព្រំដីព្រៃ ភ្នំ បឹង ជំនឿ ប្រាសាទ ទីតាំងវប្បធម៌ធម្មជាតិ ឈរលើការចង្អុលបង្ហាញតាមស្ថានភាពជាក់ស្តែងដោយជនជាតិដើមភាគតិច និងសហគមន៍ជិតខាង ហើយមានអាជ្ញាធរចូលរួមដឹងឮ** "។ មិនគួរកំណត់ទំហំដី ព្រៃ ភ្នំជំនឿ និងតំបន់ទាំងនេះនៅត្រឹម ៧ ហិកតា ដូចអនុក្រឹត្យលេខ ៨៣ ស្តីពីនីតិវិធី និងដំណើរការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ជាកម្មសិទ្ធិសមូហភាពឡើយ។ មូលហេតុ គឺដោយសារតែទំនៀមទម្លាប់ប្រពៃណី វប្បធម៌របស់ជនជាតិដើមភាគតិចមិនដែលវាស់វែង ឬដឹងថា ទីតាំង ទំហំដី ព្រៃ ភ្នំដែលជាកន្លែងអារក្ស អ្នកតាស័ក្តិសិទ្ធមានទំហំប៉ុន្មានហិកតាឡើយ គឺអាស្រ័យតាមស្ថានភាពទីតាំង ទំហំនៃការប្រតិបត្តិជាក់ស្តែង។ ដូច្នេះប្រសិនបើសេចក្តីព្រាងវិសោធនកម្មច្បាប់ថ្មីទាំងពីរនេះ ក៏បានបញ្ញត្តិកំរិតទំហំដីព្រៃអារក្សដីកប់ខ្មោច ដូចមាត្រា ៦ នៃអនុក្រឹតលេខ ៨៣ ស្តីពីនីតិវិធី និងដំណើរការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចជាកម្មសិទ្ធិសមូហភាពដែលកំពុងនៅជាធរមាន គឺពិតជាប៉ះពាល់ រំលោភ និងជាទម្រង់នៃការរើសអើងលើសិទ្ធិជំនឿ វប្បធម៌ និងសង្គមជនជាតិដើមភាគតិចក្នុងកម្រិតច្បាប់ជាតិដែលផ្ទុយពីមាត្រា ៣១ និងមាត្រា ៤៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ រួមទាំងច្បាប់វប្បធម៌ និងសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច ដែលរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានបោះឆ្នោតគាំទ្រឆ្នាំ ២០០៧។

សរុបលទ្ធផលជារួមមកសហគមន៍ជនជាតិដើមភាគតិចបានឯកភាពគ្នាថា សេចក្តីព្រាងវិសោធនកម្មច្បាប់ទាំងពីរនេះ ត្រូវតែមានចែងអំពីជំពូក និងមាត្រាដាច់ដោយឡែកជាលក្ខណៈប្រមូលផ្តុំអំពីសិទ្ធិទាំងឡាយរបស់សហគមន៍ជនជាតិដើមភាគតិច ដូចបានជម្រាបជូនក្នុងធាតុចូលទាំង ៨ ចំណុចខាងលើ។

ជាមួយគ្នានេះដែរ កិច្ចពិគ្រោះយោបល់ ក៏បានពិនិត្យជាក់លាក់តាមមាត្រានីមួយៗ នៃច្បាប់ស្តីពីព្រៃឈើឆ្នាំ ២០០២ និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិឆ្នាំ ២០០៨ ដោយបានឆ្លុះបញ្ចាំងជាមួយនឹងស្ថានភាពនៃការប្រតិបត្តិតាមបែបប្រពៃណី ខ្លឹមសារច្បាប់ និងការអនុវត្តច្បាប់ គឺសហគមន៍ជនជាតិដើមភាគតិចបានសម្រេច រៀបចំ និងប្រមូលផ្តុំដាក់ធាតុចូលតាមជំពូក និងមាត្រាជាក់លាក់ដាច់ដោយឡែកដែលពាក់ព័ន្ធអំពីសិទ្ធិជនជាតិដើមភាគតិច ដើម្បីងាយស្រួលក្នុងការពិនិត្យ និងទទួលយកដាក់ចូលក្នុងសេចក្តីព្រាងវិសោធនកម្មច្បាប់ទាំងពីរ។

ដូចច្នេះយើងខ្ញុំដែលជាតំណាងជនជាតិដើមភាគតិចទាំង ១៦ជាតិពន្ធុសង្ឃឹមយ៉ាងមុតមាំថា ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងយុត្តិធម៌ គ.ជ.អ.ប គណៈរដ្ឋមន្ត្រី រដ្ឋសភា ព្រឹទ្ធសភា និងព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជានឹងទទួលយកធាតុចូលទាំងអស់ដែលបានលើកឡើងក្នុងសេចក្តីថ្លែងការរួមនេះ ដើម្បីជាប្រយោជន៍ចំពោះជនជាតិដើមភាគតិច និងសុខសន្តិភាពសម្រាប់ប្រទេសជាតិខ្មែរយើងទាំងមូល។